00507506

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

D197/5/8

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préli

តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ៣០)

នៅចំពោះមុខ៖
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នេយ ធុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 04 / 05 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / 05 / 2010
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

កាលបរិច្ឆេទ៖ ៤ ខែ ឧសភា ឆ្នាំ២០១០

---

## សាធារណៈ

## សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំធ្វើមោឃភាពដោយមូលហេតុរំលោភនីតិវិធី

---

**សហព្រះរាជអាជ្ញា**

ជា លាង Andrew CAYLEY
យ៉ែត ចរិយា William SMITH
សេង ប៊ុនឃាង
Vincent de WILDE d'ESTMAEL

**ជនត្រូវចោទ**

ខៀវ សំផន

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ទី ចាន់ឌី
Mahdev MOHAN

**សហមេធាវីការពារជនត្រូវចោទ**

ស សុវាន
Jacques VERGÈS

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

Lima Thuy NGUYEN
គឹម ម៉េងឃី

ម៉ុច សុវណ្ណារី

Elizabeth-Joelle RABESANDRATANA

Annie DELAHAIE

Philippe CANNONE

Martine JACQUIN
Fabienne TRUSSES-NAPROS

Françoise GAUTRY

Isabelle DURAND

Christine MARTINEAU

Laure DESFORGES
Ferdinand DJAMMEN

ឡោ ជុនធី

ស៊ិន សុវ៉ន

សំ សុគង់

ហុង គឹមសួន

គង់ ពិសី

គង់ ហេង

Silke STUDZINSKY
Olivier BAHOUGNE
Marie GUIRAUD
Patrick BAUDOIN

ជេត វណ្ណលី

ពេជ អង្គ

Julien RIVET
Pascal AUBOIN

**មេធាវីការពារក្តី**

អាង ឧត្តម

Michael G. KARNAVAS

សុន អរុណ

Michiel PESTMAN
Victor KOPPE

ផាត់ ពៅស៊ាង

Diana ELLIS

ការ សាវុត្ថ

François ROUX
Marie-Paule CANIZARES

១. **អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")** បានទទួល "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំធ្វើមោឃភាព ដោយមូលហេតុរំលោភ នីតិវិធី" ដែលប្តឹងដោយសហមេធាវីការពារជនត្រូវចោទ ខៀវ សំផន កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២00៩ ("បណ្តឹងឧទ្ធរណ៍")[១]។

## I. ប្រវត្តិនីតិវិធី

២. កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២00៩ សហមេធាវីការពារក្តីរបស់ជនត្រូវចោទ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ហើយនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២00៩ សហមេធាវីការពារបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើរបស់ខ្លួនសុំធ្វើមោឃភាពដោយមូលហេតុរំលោភនីតិវិធី[២]។

៣. បណ្តឹងឧទ្ធរណ៍ត្រូវបានជូនដំណឹងជាភាសាអង់គ្លេស កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២00៩។ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២00៩ សហព្រះរាជអាជ្ញាបានដាក់សារណាតបរបស់ខ្លួន តបទៅបណ្តឹងឧទ្ធរណ៍នេះ ("សារណាតបរបស់សហព្រះរាជអាជ្ញា")[៣]។ សារណាតបនេះត្រូវបានជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២00៩។

៤. ដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សារណាតបទៅបណ្តឹងឧទ្ធរណ៍នេះទេ។

៥. កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានសម្រេចថា បណ្តឹងឧទ្ធរណ៍នេះនឹងត្រូវសម្រេច ដោយផ្អែកតែទៅលើសារណាជាលាយលក្ខណ៍អក្សរ របស់ភាគីតែប៉ុណ្ណោះ ហើយអង្គបុរេជំនុំជម្រះ បានអនុញ្ញាតឱ្យសហមេធាវីការពារក្តីរបស់ ខៀវ សំផន ដាក់ចម្លើយតប

[១] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំធ្វើមោឃភាពដោយមូលហេតុរំលោភនីតិវិធី ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២00៩ ឯកសារលេខ D197/5/1។

[២] "ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំធ្វើមោឃភាពដោយមូលហេតុរំលោភនីតិវិធី" ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២00៩ ឯកសារលេខ D197/4។

[៣] សារណាតបរបស់សហព្រះរាជអាជ្ញា តបទៅបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំធ្វើមោឃភាពដោយមូលហេតុរំលោភនីតិវិធី ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២00៩ ឯកសារលេខ D197/5/2។

00507509



ទៅសារណារបស់សហព្រះរាជអាជ្ញាក្នុងអំឡុងពេលកំណត់ចំនួន ៥ (ប្រាំ) ថ្ងៃ[៤]។ នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១០ សហមេធាវីការពារបានដាក់សំណើសុំការពិចារណាឡើងវិញទៅលើសេចក្តីសម្រេចនេះ ដោយសហមេធាវីការពារស្នើសុំឱ្យអង្គបុរេជំនុំជម្រះកំណត់កាលបរិច្ឆេទ សម្រាប់បើកសវនាការជាសាធារណៈ ឬជាជម្រើសមួយទៀត សុំការអនុញ្ញាតឱ្យជនត្រូវចោទមានរយៈពេលចំនួន៥ (ប្រាំ) ថ្ងៃចាប់ពីពេលជូនដំណឹងអំពីសារណាតបរបស់សហព្រះរាជអាជ្ញាដាក់ជាភាសាបារាំង ដើម្បីឱ្យខ្លួនអាចដាក់ចម្លើយតបបាន[៥]។

៦. នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានបដិសេធសំណើសុំការពិចារណាឡើងវិញនេះ ហើយបានបញ្ជាក់ថា កាលបរិច្ឆេទកំណត់សម្រាប់ការដាក់ចម្លើយតប គឺចាប់ផ្តើមពីការចេញសេចក្តីជូនដំណឹងអំពីសារណាតបរបស់សហព្រះរាជអជ្ញា ដាក់ជាភាសាដែលស្នើឡើងដោយភាគីដែលមានសិទ្ធិដាក់ចម្លើយតប[៦]។ សារណាតបរបស់សហព្រះរាជអាជ្ញាត្រូវបានជូនដំណឹងដល់ភាគីជាភាសាបារាំង នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០។ ដោយពិចារណាទៅលើបញ្ហាបច្ចេកទេសមួយចំនួនក្នុងការជូនដំណឹងដល់ភាគី អំពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះ កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ បានសម្រេចអនុញ្ញាតឱ្យសហមេធាវីការពារអាចដាក់ចម្លើយតបរបស់ខ្លួនយឺតបាន[៧]។ សហមេធាវីការពារក្តីបានដាក់ចម្លើយតបរបស់ខ្លួន តបទៅសារណាតបរបស់សហព្រះរាជអាជ្ញា នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១០ តាមការបង្គាប់របស់អង្គបុរេជំនុំជម្រះ។

## សេចក្តីសង្កេតទូទៅរបស់អង្គបុរេជំនុំជម្រះ

---

[៤] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរ និងសេចក្តីបង្គាប់ឱ្យដាក់ចម្លើយតប ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ ឯកសារលេខ D197/5/3។

[៥] សំណើសុំឱ្យពិចារណាឡើងវិញ"សេចក្តីសម្រេចក្នុងការសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរនិងសេចក្តីបង្គាប់ឱ្យដាក់ការឆ្លើយតប," ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារលេខ D197/5/4។

[៦] សេចក្តីសម្រេចលើសំណើសុំពិចារណាឡើងវិញលើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរ និងសេចក្តីបង្គាប់ឱ្យដាក់ចម្លើយតប ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារលេខ D197/5/5។

[៧] សេចក្តីសម្រេចឱ្យដាក់ចម្លើយតបបន្ទាប់ពីចេញសេចក្តីសម្រេចលើសំណើសុំការពិចារណាឡើងវិញលើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ឯកសារលេខ D197/5/6។

៧. នៅក្នុងសាលដីការបស់ខ្លួន សម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចបដិសេធលើសំណើសុំធ្វើមោឃភាព ("បណ្តឹងឧទ្ធរណ៍ នួន ជា")[៨] អង្គបុរេជំនុំជម្រះបានបកស្រាយសំអាងហេតុរបស់សំណើសុំធ្វើមោឃភាពនោះ តាមការបកស្រាយមាននៅក្នុងវិធានផ្ទៃក្នុង និងច្បាប់អន្តរជាតិ[៩]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា មិនមានភាគីណាមួយជំទាស់ទៅលើកំណត់សម្គាល់ទាំងនោះទេ ហើយដោយសារតែអង្គបុរេជំនុំជម្រះមិនបានកែប្រែកំណត់សម្គាល់នេះទេនោះ អង្គបុរេជំនុំជម្រះនឹងពិនិត្យមើលបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន មួយនេះ ដោយយោងទៅលើកំណត់សម្គាល់ទាំងនោះ ប៉ុន្តែមិនលើកឡើងនូវកំណត់សម្គាល់ទាំងនោះឡើងវិញទេ។

## II. **ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍**

៨. ការិយាល័យសហចៅក្រមស៊ើបអង្កេត បានចេញដីកាសម្រេចរបស់ខ្លួននៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៩ ហើយបានជូនដំណឹងដល់ភាគីជាភាសាបារាំង និងភាសាខ្មែរ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩។ សហមេធាវីការពារជនត្រូវចោទបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៩ ដោយអនុលោមតាមវិធាន ៧៥ នៃវិធានផ្ទៃក្នុង។ បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា កាលបរិច្ឆេទកំណត់ចុងក្រោយក្នុងការដាក់បណ្តឹងឧទ្ធរណ៍នេះ គឺនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៩ ដែលត្រូវជាថ្ងៃឈប់សម្រាកសម្រាប់បុគ្គលិកជាតិ ដែលជាហេតុធ្វើឲ្យការដាក់បណ្តឹងឧទ្ធរណ៍នៅថ្ងៃនោះមិនអាចធ្វើបាន។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថាបណ្តឹងឧទ្ធរណ៍នេះត្រូវបានដាក់ទាន់ពេលវេលាកំណត់។ បន្ថែមលើនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា មិនមានសកម្មភាពអ្វីធ្វើឡើងតាមមាត្រា ៩ នៃសេចក្តីណែនាំអនុវត្ត ពាក់ព័ន្ធទៅនឹងការដាក់ឯកសារឃើតយ៉ាវនៅចំពោះមុខ អ.វ.ត.ក នោះទេ។

---

[៨] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំធ្វើមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារលេខ D55/I/8។

[៩] សាលដីកា នួន ជា កថាខណ្ឌ៣២-៤២។

៩. នៅក្នុងសាលដីកា នួន ជា អង្គបុរេជំនុំជម្រះបានរកឃើញថាពាក្យសុំធ្វើមោឃភាពអាចត្រូវបានប្រកាសថាមិនអាចទទួលយកបាន ប្រសិនបើពាក្យសុំនោះ (១) មិនបានបង្ហាញសំអាងហេតុគ្រប់គ្រាន់ (២) ពាក់ព័ន្ធទៅនឹងដីកាដែលត្រូវបានប្ដឹងឧទ្ធរណ៍ ឬ (៣) គ្មានមូលដ្ឋានច្បាស់លាស់[១០]។

១០. នៅក្នុងសំណើសុំធ្វើមោឃភាពដោយមូលហេតុរំលោភនីតិវិធី ("ពាក្យសុំ")[១១] របស់ខ្លួន សហមេធាវីការពារជនត្រូវចោទលើកឡើងថា ដីកាសម្រេចលើសិទ្ធិ និងកាតព្វកិច្ចក្នុងការបកប្រែភាសារបស់ភាគី ("ដីកាសម្រេចស្តីពីការបកប្រែភាសា")[១២] អាចជំទាស់តវ៉ាបាន ហើយដូច្នេះខ្លួនបានស្នើដល់សហចៅក្រមស៊ើបអង្កេតប្ដឹងទៅអង្គបុរេជំនុំជម្រះ ដើម្បីចាត់ទុកជាមោឃៈនូវរាល់កិច្ចស៊ើបអង្កេត និងបណ្ដឹងទាំងអស់ ដោយមូលហេតុរំលោភនីតិវិធី។

១១. នៅក្នុងពាក្យសុំនោះ សហមេធាវីការពារក្ដី បានយោងទៅលើទឡ្ហីករណ៍ដែលខ្លួនបានលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ប្ដឹងប្រឆាំងនឹងដីកាសម្រេចស្ដីពីការបកប្រែភាសា។ បន្ថែមលើនេះ សហមេធាវីការពារក្ដីបានលើកទឡ្ហីករណ៍ថ្មីមួយចំនួន ដែលនឹងត្រូវសង្ខេបនៅក្នុងសាលដីកានេះ។ ពាក់ព័ន្ធទៅនឹងភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍នេះ អង្គបុរេជំនុំជម្រះ កត់សម្គាល់ឃើញថា ពាកសុំនេះបានបង្ហាញសំអាងហេតុគ្រប់គ្រាន់ និងមានមូលដ្ឋានច្បាស់លាស់។

១២. អង្គបុរេជំនុំជម្រះរកឃើញថា ពាក្យសុំនេះមានភាពពាក់ព័ន្ធទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលមិនអាចប្ដឹងឧទ្ធរណ៍បាន ដូចដែលពន្យល់យ៉ាងក្បោះក្បាយរួចហើយនៅក្នុងសាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្ដីពីការបកប្រែភាសា[១៣]។

១៣. សហព្រះរាជអាជ្ញាបានលើកឡើងថា សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបកប្រែភាសា គឺជាអាជ្ញាអស់ជំនុំ (*res judicata*) ហើយដូច្នេះ ខ្លឹមសារសាលដីកានេះ មិនអាច

---

[១០] សាលដីកា នួន ជា កថាខណ្ឌ២៤ និង ២៥។

[១១] សំណើសុំធ្វើមោឃភាពដោយមូលហេតុរំលោភនីតិវិធី ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ឯកសារលេខ D197 កថាខណ្ឌ ៥៧។

[១២] ដីកាសម្រេចអំពីសិទ្ធិនិងកាតព្វកិច្ចក្នុងការបកប្រែភាសារបស់ភាគី ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ឯកសារលេខ A190។

[១៣] សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចអំពីសិទ្ធិ និងកាតព្វកិច្ចក្នុងការបកប្រែភាសារបស់ភាគី ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារលេខ A190/I/20។



E.C.C.C * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ជាប្រធានបទសម្រាប់សំណើសុំធ្វើមោឃភាព ដូចដែលលើកឡើងដោយសហមេធាវីការពារក្តីរបស់ជនត្រូវចោទនោះទេ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ក្នុងការដោះស្រាយ លើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការបកប្រែភាសា ខ្លួនបានពិនិត្យថាតើដីកាសម្រេចនោះបានរំលោភលើផលប្រយោជន៍ទាំងឡាយណាដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងដែរឬទេ ដើម្បីសម្រេចថា តើអង្គបុរេជំនុំជម្រះមានកាតព្វកិច្ចក្នុងការប្រកាសថា បណ្តឹងនោះអាចទទួលយកបានតាមវិធានដែរឬទេ។ ដូច្នេះ អង្គជំនុំជម្រះមិនបានផ្តល់សេចក្តីសម្រេចចុងក្រោយណាមួយចំពោះដីកាសម្រេច ដែលអាចជាអាជ្ញាអស់ជំនុំនោះទេ។ អង្គបុរេជំនុំជម្រះគ្រាន់តែធ្វើការសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍នោះ មិនអាចទទួលយកបាន ហើយគ្រប់កាលៈទេសៈទាំងអស់ដីកាសម្រេចនោះ មិនអាចត្រូវប្តឹងឧទ្ធរណ៍បានទេ បើទោះជាអនុវត្តវិធាន ២១ នៃវិធានផ្ទៃក្នុងក៏ដោយ។ ហេតុដូច្នេះ សាលដីការបស់អង្គបុរេជំនុំជម្រះមួយនេះ មិនមានឥទ្ធិពលទៅលើភាពអាចទទួលយកបាននៃពាក្យសុំធ្វើមោឃភាព នាពេលបច្ចុប្បន្ននេះទេ។

## III. សំអាងហេតុក្នុងសំណើសុំធ្វើមោឃភាព

### ក. សារណារបស់ភាគី

១៤. សហមេធាវីការពារក្តីរបស់ជនត្រូវចោទ ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបានបដិសេធសំណើរបស់ខ្លួនស្នើសុំធ្វើមោឃភាព និងស្នើសុំឱ្យអង្គបុរេជំនុំជម្រះ (១) ប្រកាសមោឃភាពលើដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចក្នុងការបកប្រែភាសារបស់ភាគី (២) ធ្វើមោឃភាពលើរាល់កិច្ចស៊ើបអង្កេត និងបណ្តឹងទាំងអស់ ដោយមូលហេតុរំលោភនីតិវិធី និង (៣) បង្គាប់ឱ្យដោះលែងជនត្រូវចោទ[១៨]។ សហមេធាវីការពារក្តីផ្តល់សំអាងហេតុថា លក្ខខណ្ឌតម្រូវសម្រាប់ការធ្វើមោឃភាពដូចចែងក្នុងវិធាន៤៨ នៃវិធានផ្ទៃក្នុង និងមាត្រា២៥២ នៃក្រមនីតិវិធី

[១៨] សារណាបណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៥១។

ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបំពេញ[១៥]។ ពោលគឺ៖ មានកំហុសនីតិវិធី និងកំហុសនីតិវិធីនេះធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទ[១៦]។

១៥. សហមេធាវីបានលើកឡើងថាដីកាសម្រេចលើការបកប្រែ បណ្តាលឲ្យមានកំហុសនីតិវិធីជាសារវ័ន្ត ដោយសារដីកាសម្រេចនេះអនុញ្ញាតឲ្យឯកសារមួយផ្នែកធំក្នុងសំណុំរឿង ស្ថិតនៅជាឯកសារគ្មានការបកប្រែ[១៧]។ សហមេធាវីបានលើកឡើងថា សេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង លើការបកប្រែក្នុងសំណុំរឿងលេខ ០០១ ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង") បញ្ជាក់ការទទួលស្គាល់ទឡ្ហីករណ៍របស់សហមេធាវី[១៨]។ ដើម្បីគាំទ្រការអះអាងថា មានកំហុសនីតិវិធី សហមេធាវីបានលើកឡើងថា ឯកសារជាច្រើនក្នុងសំណុំរឿង មានតែជាភាសាខ្មែរ និង/ឬភាសាអង់គ្លេស[១៩] ហើយការបកប្រែឯកសារទាំងនេះ មិនត្រូវបានធ្វើឡើងជាប្រព័ន្ធ ឬទាន់ពេលវេលាទេ ហើយក្នុងករណីខ្លះ ទាល់តែមានសំណើពីភាគី[២០] ទើបមានការបកប្រែ។

១៦. សហមេធាវីក៏បានលើកឡើងផងដែរថា កំហុសនីតិវិធីនេះ បានបំពានលើសិទ្ធិជនត្រូវចោទក្នុងការទទួលបានការការពារដោយមេធាវីតាមការជ្រើសរើសរបស់ខ្លួន សិទ្ធិរបស់មេធាវីក្នុងការពិនិត្យសំណុំរឿង សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការតំណាង ដែលមានប្រសិទ្ធភាព គោលការណ៍សមភាពនៃការការពារក្តី និងភារកិច្ចនៃអំណាចតុលាការក្នុងការធានានូវសិទ្ធិរបស់ជនត្រូវចោទ[២១]។

១៧. សហមេធាវីក៏បានយោងទៅរកយុត្តិសាស្ត្រអន្តរជាតិដោយលើកឡើងថាស្ថានភាពនៃភាពមិនប្រក្រតី ឬ កំហុសធ្ងន់ក្នុងដំណើរការនីតិវិធីមុនអង្គសេចក្តី អាចនាំឲ្យនីតិវិធីក្លាយទៅជាមោឃៈ ទ្រឹស្តីស្តីពីការបំពាននីតិវិធី[២២]។

---

[១៥] សារណាបណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៩។

[១៦] សារណាបណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ១០។

[១៧] សារណាបណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី២០-២២។

[១៨] សារណាបណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី១៥។

[១៩] សារណាបណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី២០។

[២០] សារណាបណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី៣៦-៤៨។

[២១] សំណើសុំមោឃភាព កថាខណ្ឌទី៧។

[២២] សារណាបណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី៥០។

១៨. សហព្រះរាជអាជ្ញាបានលើកឡើងថាបណ្តឹងឧទ្ធរណ៍ មិនអាចទទួលយកបានទេ ពីព្រោះបណ្តឹងនេះត្រូវបានរារាំងដោយ *អាជ្ញាអស់ជំនុំ* ដោយសារតែបញ្ហាដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍នេះ គឺពាក់ព័ន្ធទៅនឹងសិទ្ធិទទួលបានការបកប្រែរបស់ជនត្រូវចោទ ដែលត្រូវបានវិភាគយ៉ាងល្អិតល្អន់រួចហើយដោយអង្គបុរេជំនុំជម្រះ តាមរយៈសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទប្រឆាំងនឹងដីកាសម្រេចលើការបកប្រែ[២៣]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងដែរថា គ្មានអង្គហេតុណាមួយកើតឡើង ដើម្បីគាំទ្រឱ្យមានសវនាការលើបញ្ហាដដែលនោះឡើងវិញឡើយ[២៤]។

១៩. សហព្រះរាជអាជ្ញាបានលើកឡើងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង មិនមានអានុភាពទៅលើដំណាក់កាលស៊ើបអង្កេតក្នុងដំណើរការនីតិវិធីទេ ប៉ុន្តែទោះជាយ៉ាងណាក្តី វាស្របគ្នានឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើការបកប្រែ[២៥]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូងគ្មានអំណាចបដិសេធសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដើម្បីគាំទ្រដីកាសម្រេចលើការបកប្រែនោះទេ[២៦]។

២០. សហព្រះរាជអាជ្ញាបានលើកឡើងថា តាមបញ្ញត្តិដែលបានកំណត់ក្នុងវិធាន ២១ គ្មានកំហុសនីតិវិធីណាមួយបំពានលើសិទ្ធិរបស់ជនត្រូវចោទឡើយ[២៧]។ តាមពិត សហមេធាវីបានយោងទៅរកសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការបកប្រែ ដើម្បីគាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួនថាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនត្រូវចោទ ដែលមិនរាប់បញ្ចូលនូវការបកប្រែសំណុំរឿងទាំងមូល[២៨]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ជនត្រូវចោទគួរតែចាត់វិធានការ ដើម្បីសម្រាលបញ្ហានៃការបកប្រែ ប៉ុន្តែផ្ទុយទៅវិញ បានសម្រេចចិត្តមិនប្រើធនធាន និងឱកាសដែលមានឡើយ[២៩]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា

---

[២៣] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី ១៩-២០។

[២៤] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី ២១-២៣ ។

[២៥] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី ២៤-២៩ ។

[២៦] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី៣០-៣២។

[២៧] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី៣៣-៣៤។

[២៨] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី៣៥។

[២៩] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី៣៨-៣៩។



ECCC • CETC PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00507515



ដោយសារសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មិនត្រូវបានបំពានជាក់ស្តែងដោយដីកាសម្រេចលើបញ្ហាបកប្រែរបស់សហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះមិនអាចប្រកាសមោឃភាពកិច្ចស៊ើបសួរដោយផ្អែកលើមូលដ្ឋាននៃការបំពាននីតិវិធីបានឡើយ[៣០]។

## ខ. ការពិចារណារបស់អង្គបុរេជំនុំជម្រះ

២១. អង្គបុរេជំនុំជម្រះ តម្កល់ខ្លឹមសារនៃសំអាងហេតុក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ស្តីពីការបកប្រែ ដែលខ្លួនបានរកឃើញថាដីការបស់សហចៅក្រមស៊ើបអង្កេត គឺស្របទៅស្តង់ដារអន្តរជាតិស្តីពីសិទ្ធិបកប្រែ[៣១]។

២២. អង្គបុរេជំនុំជម្រះ បានសង្កេតឃើញថា ខ្លួនបានសម្រេចលើការរកឃើញនេះជាពិសេសចំពោះសិទ្ធិបកប្រែក្នុងដំណើរការនីតិវិធីមុនអង្គសេចក្តី។ រាល់បញ្ហាដែលសហមេធាវីជនត្រូវចោទបានលើកឡើងពាក់ព័ន្ធនឹងសិទ្ធិបកប្រែ ក្នុងដំណាក់កាលផ្សេងទៀតនៃដំណើរការនីតិវិធី មិនអាចនាំទៅរកការរកឃើញផ្សេងទៀតទេ ដោយសារលក្ខខណ្ឌតម្រូវក្នុងដំណាក់កាលមុនអង្គសេចក្តីមានលក្ខណៈខុសគ្នា ជាពិសេស ពាក់ព័ន្ធនឹងសិទ្ធិបកប្រែ។ ដោយសារតែបណ្តឹងឧទ្ធរណ៍ស្នើសុំឱ្យយកសិទ្ធិក្នុងដំណាក់កាលជំនុំជម្រះ មកអនុវត្តក្នុងដំណាក់កាលមុនអង្គសេចក្តី អង្គបុរេជំនុំជម្រះ មិនយល់ឃើញថា ខ្លួនត្រូវពិនិត្យបញ្ហានេះឱ្យបានល្អិតល្អន់ជាងនេះឡើយ។

២៣. អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា សហមេធាវីជនត្រូវចោទបានលើកឡើងថា ជនត្រូវចោទមានសិទ្ធិមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន សិទ្ធិរបស់មេធាវីនៃជនត្រូវចោទក្នុងការពិនិត្យសំណុំរឿងក្នុងដំណាក់កាលស៊ើបសួរ និងសិទ្ធិទទួលបានការតំណាងដែលមានប្រសិទ្ធភាព ហើយសហមេធាវីក៏បានលើកឡើងពីគោលការណ៍សមភាព និងតួនាទីរបស់អំណាចតុលាការក្នុងការធានាសិទ្ធិរបស់ជនត្រូវចោទផងដែរ។ អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា ក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួន សហមេធាវីបានកំរិតខ្លឹមសារអង្គហេតុ ចំពោះតែដីកាសម្រេចលើការបកប្រែ

---

[៣០] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី៤១។

[៣១] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចអំពីសិទ្ធិ និងកាតព្វកិច្ចក្នុងការបកប្រែភាសារបស់ភាគី ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារលេខ A190/I/20 កថាខណ្ឌទី៣៤-៥០។

ហើយមិនបានពន្យល់អំពីរបៀបដែលសិទ្ធិដទៃទៀតត្រូវទទួលរងអានុភាពដីកានេះតាមលក្ខខណ្ឌទាំងឡាយ ដែលពាក់ព័ន្ធនឹងសិទ្ធិដែលត្រូវបានបំពានទេ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បញ្ហានេះបានលើកឡើងយ៉ាងគ្រប់គ្រាន់ ដោយតម្កល់នូវសម្អាងហេតុដូចបានលើកឡើងនៅក្នុងកថាខណ្ឌទី២១នៃសាលដីកានេះ ។

២៤. អនុលោមតាមវិធានដែលពាក់ព័ន្ធ សំណើសុំមោឃភាព គឺសំដៅជាចម្បងទៅលើដីកាសម្រេចលើការបកប្រែ។ សហមេធាវីបានលើកឡើងបន្ថែមទៀតថា ការប្រកាសមោឃភាពដីកាសម្រេចលើការបកប្រែ នឹងនាំឱ្យកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតនិងការស៊ើបអង្កេតរបស់សហព្រះរាជអាជ្ញាត្រូវទុកជាមោឃៈតាមទ្រឹស្តីស្តីពីការបំពាននីតិវិធី។ ទោះជាយ៉ាងណាក្តី សហមេធាវីមិនបានបង្ហាញទឡ្ហីករណ៍ដែលមានមូលហេតុ ពាក់ព័ន្ធនឹងវិធីដែលទ្រឹស្តីនេះអាចអនុវត្តចំពោះករណីនេះឡើយ សហមេធាវីគ្រាន់តែបានបញ្ជាក់ថាទ្រឹស្តីនេះត្រូវអនុវត្ត "ក្នុងកាលៈទេសៈនៃករណីពិសេសដែលការបន្តការជំនុំជម្រះជនជាប់ចោទ អាចផ្ទុយនឹងសម្បជញ្ញៈយុត្តិធម៌របស់តុលាការ ដោយសារតែភាពមិនប្រក្រតី ឬកំហុសឆ្គងក្នុងដំណាក់កាលមុនអង្គសេចក្តី"[៣២]។ សហមេធាវីបានបន្តដោយមិនបានលើកមូលហេតុថា នីតិវិធីមោឃភាព ដែលបានអនុវត្តក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ នួន ជា គឺមិនមែនសម្រាប់មោឃភាពកិច្ចស៊ើបសួរទូទៅ តាមការស្នើសុំក្នុងបណ្តឹងឧទ្ធរណ៍ទេ ផ្ទុយទៅវិញនីតិវិធីនេះត្រូវបានកំណត់ឡើងសម្រាប់មោឃភាពផ្នែកទាំងឡាយ នៃដំណើរការនីតិវិធីដែលធ្វើឱ្យខូចផលប្រយោជន៍របស់ជនត្រូវចោទ[៣៣]។ ដោយសារតែបណ្តឹងឧទ្ធរណ៍នេះមានបំណងសុំមោឃភាពក្នុងលក្ខណៈទូទៅលើកិច្ចស៊ើបសួរ និងកិច្ចដែលសហព្រះរាជអាជ្ញាបានធ្វើឡើង បណ្តឹងឧទ្ធរណ៍នេះត្រូវបានបដិសេធចោល។ អាស្រ័យហេតុនេះ សំណើសុំដោះលែងជាបន្ទាន់ដែលផ្អែកលើការអះអាងមិនច្បាស់លាស់អំពីវិការៈនីតិវិធី នឹងត្រូវបដិសេធចោល។

## ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ ÷

១. ទទួលយកបណ្តឹងឧទ្ធរណ៍នេះ។

---

[៣២] សារណាបណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី៥០។

[៣៣] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ នួន ជា កថាខណ្ឌទី៣៥។

002/19-09-2007-ECCC/OCIJ (PTC30)

លេខ/No.D197/5/8

២. បដិសេធបណ្ដឹងឧទ្ធរណ៍នេះ ចាត់ទុកថាឥតបានការ។

៣. បដិសេធសំណើសុំដោះលែងជនត្រូវចោទ។

ដោយអនុលោមតាមវិធាន៧៧(១៣)នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេចនេះបិទផ្លូវមិនឱ្យមានបណ្ដឹងឧទ្ធរណ៍ទេ។

ភ្នំពេញ ថ្ងៃទី ៤ ខែឧសភា ឆ្នាំ២០១០

ចៅក្រមអង្គបុរេជំនុំជម្រះ ប្រធាន

Rowan DOWNING ន័យ ថុល Katinka LAHUIS ហួត វុទ្ធី ប្រាក់ គឹមសាន